ករុណា ការប្តេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យកាល់ម៉ែត

## Calmette's Newsletter N° 04

ខែ តុលា ២០១៧ - ធ្នូ ២០១៧

ព្រឹត្តិបត្រលេខ ៤




រៀបចំដោយ

គណៈកម្មការទស្សនាវដ្តីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ តុលា ២០១៧ - ធ្នូ ២០១៧ ទស្សនាវដ្ដីលេខ ៨


**01** ទិវាវិទ្យាសាស្ត្រ **ថែទាំរបស់គិលានុបដ្ឋាក-យិកា ឆ្នប** មន្ទីរពេទ្យកាល់ម៉ែតលើកទី ៧!

**02** សន្និសីទស្ដីអំពី “**ប្រធានផ្នែក និងគម្រោងអភិវឌ្ឍន៍សេវាថែទាំ**” នៅមន្ទីរពេទ្យកាល់ម៉ែត!

**03** **មេរោគត្រូពះ** **Helicobacter Pylori**

**04** ការថែទាំទារកតូច ឬទារកមិនទាន់គ្រប់ខែ តាមបែបមេឝូតកង់ហ្គូរូ!

**05** តើអ្វីទៅជាជំងឺទឹកនោមផ្អែម ប្រភេទទី ២! **តើគួរបារម្ភឬទេ? និងគួរបង្ការគ្រោះថ្នាក់យ៉ាងដូចម្ដេច?**

**06** **អត្ថប្រយោជន៍នៃការវាស់កំហាប់ Procalcitonin ក្នុងឈាម!**

**07** **Facebook** មន្ទីរពេទ្យកាល់ម៉ែត មានជួយសង្គ្រោះសាមី!

**08** **អាហ្វេរ៉េស៊ីស (Apheresis)!**

**09** **សំណួរចម្លើយ Quiz?** ទាក់ទងនឹងសុខភាព

ទិវាវិទ្យាសាស្ត្រ

# ថែទាំរបស់គិលានុបដ្ឋាក-យិកា ឆ្មប

## មន្ទីរពេទ្យកាល់ម៉ែតលើកទី ៧!








នៅថ្ងៃព្រហស្បតិ៍ ទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៧ មន្ទីរពេទ្យបានប្រារព្ធធ្វើ ទិវាវិទ្យាសាស្ត្រថែទាំរបស់គិលានុបដ្ឋាក-យិកា ឆ្មប មន្ទីរពេទ្យកាល់ម៉ែតលើកទី ៧ ស្តីពី “ការថែទាំប្រកបដោយគុណភាព ជំនាញ លើការថែទាំមុន-ក្រោយវះកាត់ និងការថែទាំទូទៅនៅក្នុងមន្ទីរពេទ្យ” ដោយមានការចូលរួមពីសិក្ខាកាមដែលនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ព្រមទាំងបណ្តាមន្ទីរពេទ្យជាតិនៅរាជធានីភ្នំពេញ។

ក្នុងទិវានេះដែរ មានការចូលរួមធ្វើបទបង្ហាញក្រោមប្រធានបទរួមមាន៖

- ការរៀបចំ និងធ្វើសំអាតស្បែកមុនពេលវះកាត់
- ការគ្រប់គ្រងថែទាំក្រោយពេលវះកាត់ ក្រពេញប្រូស្តាត
- ការតាមដានក្រោយពេលវះកាត់
- Prevention and Monitoring Nausea Vomiting post operative
- វិធីសាស្ត្រនៃការផ្តល់ចំណីអាហារសម្រាប់អ្នកជំងឺសម្រាកពេទ្យ
- ការគ្រប់គ្រងការថែទាំស្ត្រីមានផ្ទៃពោះមុនពេលសម្រាល
- ការថែទាំជំងឺ Infarction Myocard
- ការគ្រប់គ្រងលើការយកវត្ថុវិភាគ សម្រាប់មន្ទីរពិសោធន៍បាក់តេរីសាស្ត្រ
- ទម្លាប់ទាំង ៧យ៉ាង សម្រាប់វិជ្ជាជីវៈថែទាំ។

គោលបំណងចម្បងនៃការរៀបចំទិវាវិទ្យាសាស្ត្រថែទាំ គឺសំដៅបន្តពង្រឹង និងបន្ថែមការអភិវឌ្ឍន៍សមត្ថភាព និងបទពិសោធន៍ជំនាញក្នុងការងារថែទាំប្រកបដោយប្រសិទ្ធភាព គុណភាព និងជាពិសេសការផ្តោតសំខាន់លើទំនាក់ទំនងផ្ទាល់ជាមួយអ្នកជំងឺ និងក្រុមគ្រួសារ ក្នុងទិសដៅបង្កើនកិច្ចសហការ និងការចូលរួមគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ ដើម្បីប្រសិទ្ធភាព និងសុវត្ថិភាពនៃការថែទាំព្យាបាលកម្រិតខ្ពស់បំផុតសំរាប់អ្នកជំងឺយើងទាំងអស់គ្នា។







# សន្និសីទស្តីអំពី “ប្រធានផ្នែក និងគំរោងអភិវឌ្ឍន៍សេវាថែទាំ” នៅមន្ទីរពេទ្យកាល់ម៉ែត!







ក្នុងក្របខណ្ឌនៃវគ្គបណ្តុះបណ្តាលបន្ត និងទិសដៅបង្កើនកិច្ចអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រង និងភាពជាអ្នកដឹកនាំសំរាប់បុគ្គលិក មន្ត្រីរាជការផ្នែកវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ នាថ្ងៃទី០៨ ធ្នូ ឆ្នាំ២០១៧ មន្ទីរពេទ្យកាល់ម៉ែតបានលើកយកមកពិភាក្សារួមគ្នាអំពីប្រធានបទ ប្រធានផ្នែក និងគម្រោងអភិវឌ្ឍន៍សេវាថែទាំ។

ប្រធានបទនេះ គឺមានសារៈសំខាន់ផ្ទាល់តែម្តង សំរាប់កំរិតប្រធានផ្នែក និងនាយសាលទទួលបន្ទុកថែទាំ ត្បិតគឺជាការលើកកំពស់គុណភាព នៃការព្យាបាលថែទាំអ្នកជំងឺ ហើយក៏គឺជាប្រធានបទ ដែលមានសារៈប្រយោជន៍សំរាប់គ្រប់មន្ទីរពេទ្យផងដែរ។

វគ្គបណ្តុះបណ្តាលនេះ ក៏គឺជាឱកាសថ្មីបន្ថែមមួយទៀត ដែលនាំអោយទាំងអស់គ្នាលើកយកមកពិនិត្យ ពិចារណានូវរូបមន្ត ឬវិធីសាស្ត្រផ្សេងៗ ដែលជាការវិវត្តន៍លំនាំអន្តរជាតិ ដែលប្រទេសជឿនលឿនកំពុងអនុវត្តន៍ក្នុងមន្ទីរពេទ្យធំៗនៅលើសកលលោក។





គឺជាការថែទាំទារកតូច ឲ្យប៉ះជាប់និងស្បែកម្តាយ ដើម្បីឲ្យទារកគាត់ទទួលកំដៅពីម្តាយ។ វិធីសាស្ត្រនេះ ជាវិធីថែទាំងឹសាមញ្ញ មិនមានភាពស្មុគស្មាញ តែមានប្រសិទ្ធភាពបំផុត សម្រាប់ជួយម្តាយដែលមានទារកកើតមិនគ្រប់ខែ ឬមានគីឡូតិចពីកំណើត (តិចជាង២០០០ក្រាម)

## ក) លក្ខខណ្ឌនៃការអនុវត្តវិធីសាស្ត្រ៖

វិធីសាស្ត្រនេះ អនុញ្ញាតឲ្យធ្វើការថែទាំបានលុះត្រាតែ:

- ទារករួចផុតពីជំងឺផ្លូវដង្ហើម ជំងឺឆ្លង និងរួចផុតពីសញ្ញាគ្រោះថ្នាក់ដទៃទៀត
- ម្តាយមិនមានជំងឺឆ្លង
- ម្តាយយល់ដឹងពីការអនាម័យច្បាស់
- មានក្រុមគ្រួសារជួយ(យាយ អ៊ំ ពូ មីង...)

## ខ) វិធីនៃការដាក់ឲ្យទារកប៉ះជាប់និងស្បែកម្តាយ៖

វិធីនៃការដាក់ឲ្យទារកប៉ះជាប់និងស្បែកម្តាយ ត្រូវអនុវត្តដូចខាងក្រោម:

- ចំពោះទារក ត្រូវស្លៀកតែខោទឹកនោម ខ្លួនរបស់គាត់នៅទទេមិនបាច់ពាក់អាវទេ តែត្រូវពាក់មួក ស្រោមជើង និងស្រោមដៃដើម្បីជួយការពារការបាត់កំដៅ។
- ចំពោះម្តាយ ត្រូវមានអាវជាតិអំបោះពាក់ខាងក្នុងមួយ និងអាវពាក់ពីក្រៅមួយ (ដូចក្នុងរូប) ហើយម្តាយត្រូវមានអនាម័យខ្លួន និងដៃឲ្យបានស្អាត។
- ដាក់ក្បាលទារក នៅចន្លោះទ្រូងម្តាយ
- មុខទារក ត្រូវងាកមកឆ្វេង ឬស្តាំ ជៀសវាងមុខផ្កាប់លើទ្រូងម្តាយ
- ជើងទាំពីររបស់ទារក ត្រូវនៅក្នុងអាវម្តាយក្នុងសភាពដូចកង្កែប។

## គ) ផលប្រយោជន៍នៃការថែទាំនេះ៖

- ទារកបានទទួលកំដៅគ្រប់គ្រាន់ពីម្តាយ:

ទារកដែលមានគីឡូពីកំណើតតិច ឬមិនគ្រប់ខែ សរីរាង្គរបស់គាត់ងាយនិងបាត់បង់កម្តៅ ដោយសារប្រព័ន្ធការពារកំដៅរបស់គាត់ខ្សោយ ហើយទារកតូចៗពុំមានស្រទាប់ជាតិខ្លាញ់នៅក្នុងខ្លួនទេ។

ការបាត់បង់កំដៅចំពោះទារកតូចៗ និងមិនគ្រប់ខែ អាចបណ្តាលឲ្យទារមានគ្រោះថ្នាក់ដល់អាយុជីវិតរយ:ពេលខ្លី។

- ទារកឆាប់ចង់បៅ:

ទារកទើបនិងកើត ពុំអាចមើលឃើញមុខម្តាយគាត់ទេតែគាត់ធំក្លិនម្តាយគាត់ ដែលក្លិននេះអាចរំញោចឲ្យទារកចង់បៅដោះម្តាយ ដែលជាហេតុធ្វើឲ្យទារកឆាប់ឡើងទម្ងន់។

- ទារកអាចដកដង្ហើមបានទៀងទាត់:

ទារកមិនគ្រប់ខែ ប្រព័ន្ធផ្លូវដង្ហើមដែលមាននៅផ្នែកខួរក្បាលរបស់គាត់នៅខ្ចីនៅឡើយ ដែលងាយធ្វើឲ្យទារកឆាប់ភ្លេចដកដង្ហើម។ ការដាក់ទារកនៅលើទ្រូងម្តាយ ធ្វើឲ្យគាត់ស្តាប់ឮចង្វាក់បេះដូងម្តាយ ដែលការស្តាប់ឮនេះ រំញោចឲ្យទារកធ្វើការដកដង្ហើមទៀងទាត់មកវិញ។

- កាត់បន្ថយការឆ្លងរោគក្នុងមន្ទីរពេទ្យ:

ទារកតូច ឬមិនគ្រប់ខែមានប្រព័ន្ធការពារសរីរាង្គខ្ចី ឬខ្សោយ ដូចនេះទារកស្ថិតក្នុងកន្លែងសង្គ្រោះយូរ ងាយនឹងចាប់យកមេរោគពីខាងក្រៅ ដែលបង្កគ្រោះថ្នាក់ដល់ជីវិត។ ការដាក់ទារកឲ្យនៅជាមួយម្តាយ ធ្វើឲ្យទារកចង់បៅដោះម្តាយ ដែលទឹកដោះម្តាយសម្បូរទៅដោយប្រព័ន្ធការពារ(អង់ទីករ) ជួយទារករួចផុតពីការឆ្លងរោគក្នុងមន្ទីរពេទ្យ។

- បង្កើតទំនាក់ទំនងស្និទ្ធស្នាលរវាងម្តាយនិងកូនតូចរបស់គាត់ ដែលធ្វើឲ្យគាត់បាត់អារម្មណ៍តានតឹងពីការថែទាំកូនរបស់គាត់ និងធ្វើឲ្យគាត់មានភាពម្ចាស់ការក្នុងការថែទាំទារកនៅពេលគាត់ចេញទៅផ្ទះ ហើយការថែទាំតាមវីធីកង់ហ្គូរូនេះ ជួយកាត់បន្ថយការសម្រាកពេទ្យយូរ។



# ការថែទាំទារកតូច ឬទារកមិនទាន់គ្រប់ខែ តាមបែបមេតូតកង់ហ្គូរូ!



■ ម្តាយគ្រប់រូបនៅពេលដែលប្រសូតបុត្រមកមានទម្ងន់តិច( ទារកមានគីឡូតិចជាង ២០០០ក្រាម) ឬមិនគ្រប់ខែ តែងមានអារម្មណ៍ពិបាកចិត្តក្នុងការថែទាំកូនជាទីស្រឡាញ់របស់ខ្លួន ហើយមួយទៀតកូនតូចរបស់គាត់ត្រូវនៅឆ្ងាយពីខ្លួនមិនបានឱបជាប់និងខ្លួនដូចគេ ទារកក៏ដូចគ្នាគឺនៅឆ្ងាយពីម្តាយ។ ដូចនេះការថែទាំទារកមិនគ្រប់ខែ ឬមិនគ្រប់គីឡូតាមបែបវិធីសាស្ត្រកង់ហ្គូរូ បានជួយបង្កើតឲ្យម្តាយមានអារម្មណ៍ធូរស្រាលវិញនៅពេលឃើញកូនរបស់គាត់រាល់ថ្ងៃ។ ឮប្រសិទ្ធភាពនៃការថែទាំតាមបែបវិធីសាស្ត្រនេះ គឺអាស្រ័យលើពេលវេលា។ បើ ម្តាយដាក់កាន់តែយូរ ប្រសិទ្ធភាពកាន់តែល្អ ព្រោះកូនបានទទួលកំដៅពីម្តាយគ្រប់គ្រាន់ ធ្វើឲ្យទារកឡើងគីឡូបាន។

នៅពេលគាត់ដាក់ទារកលើទ្រូងរបស់គាត់ គ្រូពេទ្យនិងគិលានុដ្ឋាយិកាជំនាញនឹងពន្យល់អំពីការតាមដានសភាពកូន ពណ៌សម្បុរ ការដកដង្ហើម និងកម្តៅរបស់កូនតូចគាត់។ មន្ទីរពេទ្យកាល់ម៉ែតបានរៀបចំវិធីនេះតាំងពីឆ្នាំ ២០១០ ដែលមានគ្រូពេទ្យនិងគិលានុដ្ឋាយិកាជំនាញក្នុងការថែទាំទារកមិនគ្រប់ខែ ឬមិនគ្រប់គីឡូ ដោយមានប្រសិទ្ធិភាពខ្ពស់។

យើងខ្ញុំសូមធ្វើការផ្តាំផ្ញើដល់ម្តាយគ្រប់រូបដែលមានទារកតូច ដោយសាររដូវនេះជារដូវរំហើយ អាកាសធាតុចុះត្រជាក់នៅពេលព្រឹក សូមមេត្តាថែទាំទារកឲ្យបានល្អ និងប្រុងប្រយ័ត្ននូវការបាត់បង់កម្តៅរបស់កូន ដែលជាហេតុបង្កឲ្យទារកតូចនោះមានជំងឺ ឬបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិត។

“សុខភាពកូនលោកអ្នក ជាភារកិច្ចដ៏ថ្លៃថ្លារបស់យើងខ្ញុំជាគ្រូពេទ្យ ហើយទារកគ្រប់រូបជាទំពាំងស្នងឬស្សីរបស់ប្រទេសយើង!”



# តើអ្វីទៅជាជំងឺទឹកនោមផ្អែម ប្រភេទទី ២! **តើគួរបារម្ភឬទេ? និងគួរបង្ការគ្រោះថ្នាក់យ៉ាងដូចម្តេច?**

ជំងឺទឹកនោមផ្អែមប្រភេទទី ២ កើតមាននៅពេលដែល រាងកាយមនុស្សយើង មិនអាចប្រើប្រាស់អាំងស៊ុយលីនបានល្អតាមតម្រូវការ។ អាំងស៊ុយលីនជាអ័រម៉ូន ដែលដឹកនាំជាតិស្ករក្នុងឈាមយកទៅបំលែងទៅជាថាមពលប្រើប្រាស់នៅគ្រប់កោសិកាយើង។

បើមិនបានព្យាបាល ជំងឺនេះបណ្តាលឲ្យមានផលវិបាកធ្ងន់ធ្ងរជាច្រើនដូចជា៖

-ខ្សោយតម្រងនោម
- ស្លាប់សាច់ដុំបេះដូង ដោយស្ទះសរសៃឈាម
- ដាច់ ឬស្ទះសរសៃឈាមខួរក្បាល
- ជំងឺភ្នែក (ពិការភ្នែក)
- កាត់ជើង ដោយសារក្លាយរោគធ្ងន់ធ្ងរ




ដំបូន្មានទូទៅសម្រាប់អ្នកជំងឺទឹកនោមផ្អែម៖

- ហាត់ប្រាណយ៉ាងតិច ៣០នាទីក្នុងមួយថ្ងៃ ៥ថ្ងៃក្នុង១សប្តាហ៍
- បរិភោគអាហារមួយថ្ងៃយ៉ាងតិច ៣ដង និងទៀងពេល ដោយមានបន្លែគ្រប់មុខ និងបរិបូរណ៏
- ពិសាថ្នាំឲ្យបានទៀងទាត់ និងតាមពេលដែលបានកំណត់ដោយគ្រូពេទ្យ
- កុំពិសាស្រា ឫគ្រឿងស្រវឹងហួសប្រមាណ
- ជៀសវាងពិសាបារី
- ជៀសវាងពិសាប្រៃញ្ញីកញ្ញាប់ និងហួសប្រមាណ
- កុំដើរជើងទទេ និងត្រូវសម្អាតជើងរាល់ថ្ងៃ
- ត្រូវពិគ្រោះជាមួយគ្រូពេទ្យឲ្យបានទៀងទាត់ និងតាមដានជាតិស្ករចុងដៃជាប្រចាំ និងដោយទៀងទាត់ តាមយោបល់របស់វេជ្ជសាស្ត្រ។











ក្រុមគ្រូពេទ្យជំនាញឯកទេសនៃមន្ទីរពេទ្យកាល់ម៉ែត សូមស្វាគមន៍រាល់ការមកពិគ្រោះយោបល់ អំពីរាល់ស្ថានភាពជំងឺទឹកនោមផ្អែមប្រកបដោយបទពិសោធន៍ និងការយកចិត្តទុកដាក់ខ្ពស់បំផុត។™



# អត្ថប្រយោជន៍នៃការវាស់កំហាប់ Procalcitonin ក្នុងឈាម!

## ក) អ្វីទៅជា Procalcitonin ?

Procalcitonin (PCT) គឺជា peptide ម្យ៉ាងដែលមាននាទីផលិតអរម៉ូន Calcitonin ចូលរួមក្នុងការធ្វើ Calcium homeostasis ។ Procalcitonin ផ្សំពី 116 amino acids វាត្រូវបានផលិតដោយ Parafollicular cells (C cells) នៃក្រពេញទីរ៉ូអ៊ីត (Thyroid gland) និង Neuroendocrine cells នៃជាលិកាសួតនិងពោះវៀន ដើម្បីឆ្លើយតបនឹងការរលាក (Inflammation) ដែលបង្កឡើងពីបាក់តេរី (Bacterias)។



## ខ) តើ Procalcitonin (PCT) ត្រូវបានស្នើសុំនៅពេលណា?

Procalcitonin ជា petide ដែលត្រូវបានគ្រូពេទ្យស្នើសុំវាស់កំហាប់ របស់វានៅក្នុងឈាមនៅពេលដែលគាត់សង្ស័យថាអ្នកជំងឺមានឆ្លងមេរោគ ដែលអាចចូលទៅក្នុងឈាម(Sepsis)។ ជាគុណប្រយោជន៍ Procalcitonin ត្រូវបានគេរកដើម្បី បែងចែកការឆ្លងមេរោគរបស់ អ្នកជំងឺថាតើឆ្លងមេរោគប្រភេទបាក់តេរី (Bacterial infection) ឬជាការឆ្លងមេរោគប្រភេទ មិនមែនជាបាក់តេរី (Non-bacterial infection) ដូចជាឆ្លងដោយវីរុស (Viral infections) ឬពពួកភ្នាក់ងារឆ្លងផ្សេងៗ (Other infectious agents) ជាដើម។

គោលបំណង វាអាចជួយដល់អ្នកជំងឺ កាត់បន្ថយការប្រើប្រាស់ថ្នាំផ្សះ (Antibiotic therapy) ហើយការស្នើសុំ Procalcitonin មានប្រសិទ្ធភាពខ្ពស់នៅថ្ងៃដំបូងនៃការចេញរោគសញ្ញា។

## គ) ការបកស្រាយលទ្ធផលមន្ទីរពិសោធន៍នៃកម្រិត Procalcitonin ក្នុងឈាម

- កម្រិត Procalcitonin ទាប (low levels at procalcitonin) នៅក្នុង ឈាមរបស់ អ្នកជំងឺបង្ហាញថាមានហានិភ័យទាបសម្រាប់ការឆ្លងមេរោគ បាក់តេរី (bacterial infections) ទៅក្នុងប្រព័ន្ធសរសៃឈាម (Low risk of sepsis) ។
- កម្រិត Procalcitonin ខ្ពស់ (high levels of procalcitonin) នៅក្នុងប្រព័ន្ធសរសៃឈាម បង្ហាញពីការប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគ ចូលក្នុងឈាម(Systemic bacterial infection) ដែលអាចឲ្យអ្នកជំងឺ ប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ (Severe sepsis) នាំឲ្យបាត់បង់ជីវិត (Septic shock) ។



ជារួមការវាស់កំហាប់ Procalcitonin (PCT) នៅក្នុងឈាមពិតជាមានអត្ថប្រយោជន៍យ៉ាង សំខាន់សម្រាប់អ្នកជំងឺ ដែលធ្វើឲ្យគ្រូពេទ្យធ្វើការ ព្យាបាលបានត្រឹមត្រូវ ទៅតាមការឆ្លងមេរោគ និង កាត់បន្ថយហានិភ័យនៃ ការស៊ាំមេរោគជាមួយថ្នាំផ្សះ (antibiotic resistance) ។

មន្ទីរពិសោធន៍នៃមន្ទីរពេទ្យកាល់ម៉ែត ជាមន្ទីរពិសោធន៍ដែលធ្វើការវិភាគប្រកបដោយការយកចិត្តទុកដាក់ សំដៅសុក្រឹតភាព គុណភាព និង ប្រសិទ្ធភាព ដោយផ្អែកលើសមត្ថភាព និងបទពិសោធន៍នៃក្រុមការងារ ជំនាញនិមួយៗ ជាមួយនឹងមធ្យោបាយនៃ ការបំពាក់បរិក្ខារវេជ្ជសាស្ត្រទំនើប ៗស្តង់ដាសកល។





# Facebook
# មន្ទីរពេទ្យកាល់ម៉ែត បានជួយសង្គ្រោះសាមី!

ប្អូនស្រីសាមី ដែលជាក្មេងស្រីកំសត់ ដោយបានធ្លាក់ខ្លួនពិការជើងទាំង២កម្រើកមិនបាន។ ពីដំបូងនៅពាក់កណ្តាលឆ្នាំ២០១៦ ប្អូនស្រីចាប់ផ្តើមធ្វើទុក្ខដោយចុកចាក់ក្នុងពោះ ព្រមទាំងឆ្អឹងខ្នង។ សាមី និងក្រុមគ្រួសារបានខិតខំស្វែងរកការព្យាបាល ប៉ុន្តែជាលទ្ធផលនៅតែទទួលបានភាពអវិជ្ជមាន។ មួយរយៈក្រោយមកជើងទាំងពីរទន់ដោយគ្មានមូលហេតុ បន្ទាប់មកអាការៈនៃជំងឺនេះ បានវិវត្តន៍ទៅរកស្ថានភាពកាន់តែធ្ងន់ធ្ងរទៅរហូតដល់មិនអាច ដើរកម្រើក និងមិនអាចបញ្ជាជើងទាំងពីររបស់ខ្លួនបាន នៅក្នុងកំឡុងចុងឆ្នាំ២០១៦។

តាមរយៈវីដេអូ និងព័ត៌មានអប់រំទាក់ទងនឹងសុខភាពនៅក្នុងទំព័រ Facebook មន្ទីរពេទ្យកាល់ម៉ែត ដែលមានការស៊ែរ(Share)ចែករំលែកយ៉ាងទូលំទូលាយបានដឹងដល់ក្រុមគ្រួសារសាមីដែលធ្វើឲ្យពួកគាត់មានសង្ឃឹម និងសម្រេចចិត្តមកទទួលយកការព្យាបាល។

នៅចុងខែវិច្ឆិកា ឆ្នាំ២០១៦ ប្អូនស្រីសាមីបានចូលមកពិគ្រោះជំងឺនៅមន្ទីរពេទ្យកាល់ម៉ែតដោយស្ថានភាពជំងឺឈឺចាក់នៅឆ្អឹងខ្នង និងជើងទាំងពីរមិនអាចកម្រើក និងបញ្ជាមិនបាន។ ក្រោយពីវេជ្ជបណ្ឌិតធ្វើការពិនិត្យ និងធ្វើរោគវិនិច្ឆ័យ ឃើញថាប្អូនស្រីមានជំងឺ ដុំសរសៃប្រសាទបញ្ជា ស្ថិតនៅនឹងឆ្អឹងកងខ្នងទី៩(Neurinome rachidien T9)។ វេជ្ជបណ្ឌិតបានសម្រេចធ្វើការវះកាត់នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៦។

បន្ទាប់ពីធ្វើការវះកាត់រួច ប្អូនស្រីអាចកម្រើកជើងខ្លះៗ ១-២ខែក្រោយមកអាចដើរបាន ៧០%។ ឥឡូវប្អូនស្រីសាមីអាចដើរបានធម្មតាវិញហើយ ព្រមទាំងរត់បានទៀតផង។











ជាមួយជំហានដំណើរដ៏សមសួន មាំមួន និងស្វាហាប់ ទឹកមុខស្រស់ស្រាយដោយស្នាមញញឹមពោរពេញដោយក្តីសង្ឃឹមជាថ្មីក្នុងអនាគតដ៏ត្រចះត្រចង់ ប្អូនស្រីសាមីបានរំលេចចេញនូវអត្ថន័យអរគុណលើ Facebookមន្ទីរពេទ្យកាល់ម៉ែតដែលបានផ្តល់ពន្លឺនៃជីវិតសម្រាប់ប្អូន ក្រោមមោទនភាពនៃក្រុមវេជ្ជបណ្ឌិតជំនាញវះកាត់នៅមន្ទីរពេទ្យកាល់ម៉ែត ដែលទទួលជោគជ័យក្នុងការជួយព្យាបាលប្អូនស្រីបានសម្រេចដូចក្តីប្រាថ្នា។

# មេរោគក្រពះ Helicobacter Pylori

### ១) មេរោគក្រពះអាចបង្កជាជំងឺអ្វីខ្លះ? ហើយវាអាចបង្កជារោគសញ្ញាដូចម្តេច?

- មេរោគក្រពះ H. pylori ត្រូវបានគេរកឃើញនៅឆ្នាំ ១៩៨៤ ហើយមេរោគនេះត្រូវបានគេទទួលស្គាល់ថាជាមេរោគដែលអាចបង្កឲ្យកើតជាដំបៅក្រពះ និងមហារីកក្រពះ

- មេរោគក្រពះអាចបង្កជាជំងឺមួយចំនួនដូចជា៖
    - ជំងឺរលាកក្រពះ (100%)
    - ដំបៅក្រពះ (១០%)
    - មហារីកក្រពះ (១%)



- រោគសញ្ញារួមមាន៖
    - ចុកឆ្អល់ក្នុងពោះ
    - តឹងណែនចុងដង្ហើម
    - ក្រហាយ ឬក្តៅនៅចុងដង្ហើម
    - បត់ជើងមកពណ៌ខ្មៅ ឬមានឈាមជាដើម

២) តើធ្វើយ៉ាងណាដើម្បីឲ្យដឹងថាអ្នកជំងឺ មានមេរោគក្រពះ?

ដើម្បីធ្វើរោគវិនិច្ឆ័យថាអ្នកជំងឺមានមេរោគក្រពះឬទេ យើងត្រូវ៖
- យកកោសិកាក្រពះមកពិនិត្យ
- ធ្វើតេស្តដង្ហើម
- ធ្វើតេស្តលាមក

### ៣) ក្នុងចំណោមវិធីសាស្ត្រទាំងបីនេះ តើវិធីមួយណាដែលល្អប្រសើរជាងគេសម្រាប់រកមេរោគក្រពះ?

វិធីសាស្ត្រទាំង៣ខាងលើនេះ គឺមានប្រសិទ្ធិភាពខ្ពស់ដូចគ្នាក្នុងការរកមេរោគក្រពះ ប៉ុន្តែវាមានលក្ខណ:ពិសេសរៀងៗខ្លួន ដូចជាការយករំអិលក្រពះមកពិនិត្យ។ វិធីនេះតម្រូវចាំបាច់ឲ្យមានការសុងក្រពះដើម្បីយករំអិលក្រពះទៅពិនិត្យ ដែលអ្នកជំងឺភាគច្រើន មានការភ័យខ្លាច ប៉ុន្តែវាក៏មានផលចំណេញជាច្រើនទៀតដែរដូចជា បន្ថែមពីលើការរកមេរោគក្រពះ គឺយើងអាចធ្វើរោគវិនិច្ឆ័យបានថាអ្នកជំងឺមានបញ្ហានៅក្នុងក្រពះផ្សេងទៀតដូចជា រលាកក្រពះ ដំបៅក្រពះ និងមហារីកក្រពះជាដើម។

វាអាចជួយឲ្យគ្រូពេទ្យធ្វើការព្យាបាលនូវផលវិបាកមួយចំនួនដូចការព្យាបាលការហូរឈាមក្រពះជាដើម។ ចំណែកឯការធ្វើតេស្តលាមក និងតេស្តដង្ហើម វាមិនតម្រូវឲ្យអ្នកជំងឺត្រូវធ្វើការសុងក្រពះនោះទេ គឺការធ្វើតេស្តលាមក អ្នកជំងឺគ្រាន់តែយកលាមកមកឲ្យគ្រូពេទ្យសម្រាប់ធ្វើការពិនិត្យជាការស្រេច រីឯការធ្វើតេស្តដង្ហើមអ្នកជំងឺគ្រាន់តែធ្វើតាមការណែនាំរបស់គ្រូពេទ្យ ដោយគ្រាន់តែផ្លុំខ្យល់ចូលទៅ ក្នុងថង់រួចយកទៅពិនិត្យជាការស្រេច និងអាចទទួលបានលទ្ធផលភ្លាមៗ បន្ទាប់ពីការផ្លុំ។

### ៤) តើការធ្វើតេស្តដង្ហើមតម្រូវអោយអ្នកជំងឺត្រៀមអ្វីខ្លះ?

ការធ្វើតេស្ត តម្រូវឲ្យអ្នកជំងឺ
- តមអាហាររយ:ពេល៦ម៉ោង
- បញ្ឈប់នូវការប្រើប្រាស់ថ្នាំផ្សះរយ:ពេលយ៉ាងតិច១ខែ
- បញ្ឈប់នូវការប្រើប្រាស់ថ្នាំក្រពះរយ:ពេលយ៉ាងតិច២សប្តាហ៍

### ៥) តើអ្នកជំងឺប្រភេទណាខ្លះ ដែលគួរជ្រើសរើសយកការធ្វើតេស្តដង្ហើម?

ជាទូទៅប្រសិនបើមិនមានការចាំបាច់ក្នុងការសុងក្រពះទេ តេស្តដង្ហើមគឺស័ក្តសម បំផុតសំរាប់ធ្វើរោគវិនិច្ឆ័យ ថាអ្នកជំងឺមានមេរោគក្រពះឬទេ។ ប៉ុន្តែក្នុង




ករណីចាំបាច់ អ្នកជំងឺត្រូវធ្វើការសុងក្រពះនោះ ការយកកោសិកាក្រពះពិនិត្យ គឺជាមធ្យោបាយល្អបំផុត។

រោគសញ្ញាដែលបញ្ជាក់ថាអ្នកជំងឺគួរសុងក្រពះ រួមមាន៖
- បន្ទោរបង់មកខ្មៅ ឬមានឈាម
- អ្នកជំងឺស្រកទម្ងន់ខុសធម្មតា
- កង្វះគ្រាប់ឈាមដោយឥតមូលហេតុ
- មានអាយុលើសពី៥០ឆ្នាំ ហើយមានរោគសញ្ញាចុកឆ្អល់ចុងដង្ហើមថ្មីៗ
- ធ្លាប់កាត់ក្រពះ

### ៦) តើការមើលឈាមអាចបញ្ជាក់បានថា អ្នកជំងឺមានមេរោគក្រពះដែរឬទេ?

- ការមើលឈាមមិនអាចបញ្ជាក់បានថាអ្នកជំងឺមានមេរោគក្រពះនោះទេ។ ការមើលឈាម គ្រាន់តែអាចបញ្ជាក់បានថា អ្នកជំងឺមានប្រព័ន្ធការពារប្រឆាំងនឹងមេរោគ មិនមែនមេរោគនោះទេ។

- ការមើលឈាមឃើញ អាចមានលទ្ធផល២៖

អ្នកជំងឺអាចឆ្លងមេរោគពីមុនរួចជាទៅវិញ ឬអ្នកជំងឺមានមេរោគពិតមែន ដែលយើងមិនអាច បែងចែកដាច់ថាអ្នកជំងឺឈឺ ឬអត់។

### ៧) បើមិនមានការព្យាបាល អ្នកជំងឺអាចមានបញ្ហាអ្វីខ្លះ?

- ជាទូទៅបើមិនមានការព្យាបាលត្រឹមត្រូវរយ:ពេលមួយ អ្នកជំងឺនឹងវិវត្តន៍ទៅជារលាកក្រពះរ៉ាំរ៉ៃ ហើយអាចក្លាយទៅដំបៅក្រពះ និងជាចុងក្រោយមហារីកក្រពះ។

### ៨) តើបន្ទាប់ពីការព្យាបាល អាចការពារអ្នកជំងឺមិនឱ្យកើតមហារីកក្រពះបានដែរឬទេ?

- បើការព្យាបាលទាន់ពេលវេលា យើងអាចការពារមិនឲ្យមានជំងឺមហារីកក្រពះបាន។ប៉ុន្តែក្នុងករណីយឺតយ៉ាវ ការរលាករ៉ាំរ៉ៃ អាចធ្វើអោយកោសិកាក្រពះមានការផ្លាស់ប្តូរទៅជាស្វិត ការព្យាបាលអាចកាត់បន្ថយអត្រាមហារីកបាន ប៉ុន្តែមិនបាន១០០%នោះទេ។








# អាហ្វេរ៉េស៊ីស (Apheresis)!

ជាបច្ចេកវិទ្យាក្នុងការដកយកកោសិកាឈាមពីមនុស្ស ដើម្បីសង្គ្រោះជីវិតអ្នកជំងឺដែលកំពុងមានអាសន្នផ្នែកវិបត្តិឈាម។ ចុងសតវត្សទី ២០ នៅខែមេសា ១៩៨១ ម៉ាស៊ីនដ៏ទំនើបត្រូវបានបង្កើតឡើងជាលើកដំបូង ដើម្បីចូលរួមក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រក្នុងការដកយកកោសិកាឈាម ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

មន្ទីរពេទ្យកាល់ម៉ែត បានចាប់ផ្តើមអនុវត្តបច្ចេកទេសទំនើបនេះតាំងពីឆ្នាំ២០១៣ ក្នុងការព្យាបាលជំងឺមហារីកឈាម ជំងឺរ៉ាំរ៉ៃ និងការផ្តល់ផលិតផលឈាមដែលមានប្រសិទ្ធភាព ជួយសង្គ្រោះជីវិតអ្នកជំងឺជាច្រើន។ ក្នុងការអនុវត្តសព្វថ្ងៃនេះ យើងបានដកយកនូវកោសិកាឈាមមួយចំនួនដូចជា៖

- គ្រាប់ឈាមមហារីក
- ប្លាស្មា
- ប្លាកែត
- និងកោសិកាពូជដើម។

លើសពីនេះទៀត យើងអាចដកយកនូវសារធាតុពុលចេញពីប្លាស្មា (Therapeutic Plasma Exchange) ដើម្បីសង្គ្រោះជីវិតអ្នកជំងឺ៖

- ខ្សោយសាច់ដុំធ្ងន់ធ្ងរ (Myasthenia gravis)
- វិបត្តិកកឈាមនៅសរសៃតូចៗ (Thrombotic Thrombopenic Purpura)
- ខ្សោយសាច់ដុំដោយវិបត្តិប្រពន្ធ័សរសៃប្រសាទ (Guillain Barre Syndrom) ។ល។

មន្ទីរពេទ្យកាល់ម៉ែត បានផ្តល់ជូននូវការព្យាបាលដោយអាហ្វេរ៉េស៊ីស លើកដំបូងបង្អស់នៅកម្ពុជា និងកំពុងតែអភិវឌ្ឍបន្ថែមនូវបច្ចេកវិទ្យាថ្មីៗទៀត។








# សំណួរចម្លើយ Quiz ទាក់ទងនឹងសុខភាព



Q1. តើធ្វើយ៉ាងណាដើម្បីឲ្យដឹងថាអ្នកជំងឺមានមេរោគក្រពះ?

១. យកកោសិកាក្រពះមកពិនិត្យ

២. ធ្វើតេស្តដង្ហើម

៣. ធ្វើតេស្តលាមក

៤. ចម្លើយទាំង៣ ខាងលើ



Q2. តើមានមូលហេតុអ្វីខ្លះ ដែលបណ្តាលឲ្យស្ត្រីបែកទឹកភ្លោះមុនពេលឈឺពោះសម្រាល?

១) ការរីកតឹងនៃស្បូន ក្នុងករណីកូនភ្លោះ ឬកូនច្រើន ទឹកភ្លោះច្រើន កូនថ្លោស

២) ការបង្ករោគ (Infection)

៣) ការប៉ះទង្គិច

៤) ចម្លើយទាំងបីខាងលើ



Q3. តើ "ជំងឺក្រិនថ្លើម" បណ្តាលមកពីអ្វី?

១. ការជក់បារីច្រើន

២. ជំងឺរលាកថ្លើមប្រភេទ A

៣. ជំងឺរលាកថ្លើមប្រភេទ B, C និងការបរិភោគស្រាវរយៈពេលយូរ





សូមមេត្តាផ្ទៀងផ្ទាត់ចម្លើយដែលផ្តល់ជូននៅព្រឹត្តិបត្រលេខបន្ទាប់

ចម្លើយរបស់សំណួរនៅព្រឹត្តិបត្រលេខ ៣

សំណួរទី ១ - ចម្លើយ ២

សំណួរទ ២ - ចម្លើយ ២

សំណួរទ ៣ - ចម្លើយ ១

សំណួរទ ៤ - ចម្លើយ ៣



# ឧបត្ថមដោយ

Getz pharma · HP · C.M.P · Dexa Medica — Expertise for the Promotion of Health · ZM®

---


លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧

អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh

ហ្វេសប៊ុក: www.facebook.com/calmette.gov.kh


ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត

ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត

ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត